**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
លេខៈ......០១០......សណន.សក.ជជគ

ថ្ងៃ...អង្គារ ៣ រោច...ខែ...ផល្គុន...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី......៣០......ខែ......មីនា......ឆ្នាំ២០២១

# សេចក្តីណែនាំ
## ស្តីពី
## វិធានការនៃការបង្ការ និងទប់ស្កាត់ ការរាតត្បាតនៃជំងឺកូវីដ-១៩ ក្នុងអំឡុងពេលឈប់សម្រាកចំនួន៣ថ្ងៃ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ដល់ម្ចាស់ក្រុមហ៊ុន និងអាជីវករដឹកជញ្ជូនអ្នកដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា

អនុលោមតាមសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ចាប់ពីថ្ងៃពុធ ៣ កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤ ដល់ថ្ងៃសុក្រ ៥ កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២១ និងវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ-១៩។

ក្រសួងសាធារណការ និងដឹកជញ្ជូន សូមធ្វើការណែនាំទៅដល់ម្ចាស់ក្រុមហ៊ុន និងអាជីវករដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ត្រូវយកចិត្តទុកដាក់អនុវត្តតាមសារាចរណែនាំ និងវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ ដូចខាងក្រោមៈ

១. រក្សាគម្លាតសុវត្ថិភាព និងសម្អាតកន្លែងផ្តល់សេវាដល់អតិថិជនឱ្យបានស្អាតជានិច្ច ជាពិសេសនៅចំណតយានយន្ត បញ្ជរលក់សំបុត្រ កន្លែងរង់ចាំ កន្លែងទទួលទានអាហារ បន្ទប់អនាម័យ។ល។

២. ត្រួតពិនិត្យ និងតាមដានសុខភាពអ្នកបើកបរ និងបុគ្គលិកបម្រើសេវាជាប្រចាំ ដោយតម្រូវឱ្យពាក់ម៉ាសគ្រប់ពេលវេលា។ បើមានការសង្ស័យលើសុខភាពរបស់ពួកគាត់ ត្រូវឱ្យពួកគាត់ឈប់សម្រាក និងបញ្ជូនគាត់ទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព។

៣. ត្រូវប្រើប្រាស់ទឹកអាល់កុល ឬសារធាតុសម្លាប់មេរោគ ដើម្បីលាងសម្អាតរាល់វត្ថុទាំងឡាយនៃរថយន្ត ដែលអ្នកធ្វើដំណើរតែងប៉ះពាល់ដូចជា របារតោង ភ្ជាក់ដៃ កៅអី ទ្វារ ឱ្យបានជាប្រចាំនៅមុន និងក្រោយពេលអ្នកដំណើរឡើងចុះ។

៤. ត្រូវបើកបង្អួចរថយន្តឱ្យមានខ្យល់ចេញចូល ចៀសវាងការប្រើប្រាស់ម៉ាស៊ីនត្រជាក់ច្រើនពេក។

៥. រាល់អ្នកដំណើរមុននឹងអនុញ្ញាតឱ្យឡើងជិះយានជំនិះ ត្រូវឱ្យពាក់ម៉ាស វាស់កំដៅ ប្រើទឹកអាល់កុល ឬទឹកជែល សម្រាប់លាងដៃ និងរក្សាគម្លាតសុវត្ថិភាព។ ក្នុងករណីពិនិត្យឃើញអ្នកដំណើរមានអាការៈដូចជា

ក្តៅខ្លួនលើសពី **៣៧,៥អង្សាសេ** មានក្អក ឬឈឺបំពង់ក ឬមានបញ្ហាក្នុងការដកដង្ហើម មិនត្រូវអនុញ្ញាតឱ្យឡើងជិះរថយន្តឡើយ និងត្រូវណែនាំឱ្យគាត់ទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពដែលនៅជិតបំផុតជាបន្ទាន់ ឬទូរស័ព្ទទៅបណ្តាញទំនាក់ទំនងទាន់ហេតុការណ៍ លេខ **១១៥** របស់ក្រសួងសុខាភិបាល។

៦. ម្ចាស់ក្រុមហ៊ុន អាជីវករដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ និងអ្នកធ្វើដំណើរទាំងអស់ ត្រូវចូលរួមអនុវត្តនូវវិធានការ **«៣ការពារ និង៣កុំ»** ព្រមជាមួយនឹងវិធានការសុខាភិបាលចាំបាច់ផ្សេងៗទៀត ឱ្យបានខ្ជាប់ខ្ជួន និងគ្រប់ៗគ្នា។

៧. ម្ចាស់ក្រុមហ៊ុន អាជីវករដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ មិនត្រូវដំឡើងថ្លៃសេវាដឹកជញ្ជូនអ្នកដំណើរក្នុងឱកាសពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិខាងមុខនេះឡើយ។

ក្រសួងសាធារណការ និងដឹកជញ្ជូន សង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុន អាជីវករដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ និងប្រជាពលរដ្ឋដែលធ្វើដំណើរតាមរថយន្តដឹកជញ្ជូនអ្នកដំណើរទាំងអស់ ត្រូវចូលរួមអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

ស៊ុន ចាន់ថុល